**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៧៥ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣

# ប្រកាសអន្តរក្រសួង

## ស្តីពីការបង្កើតរដ្ឋលេខាធិការ...នៅក្រសួងពាណិជ្ជកម្ម

*******

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម / ១២៩៩ /១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបាន កែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម / ១២០២ /០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញព្រះរាជក្រម លេខ នស/រកម / ១២០២ /០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យ លេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ-មប្រក ចុះថ្ងៃទី ៧៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស ហ វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវ-ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យបុរេប្រទាន
- បានឃើញប្រកាសលេខ ១២៩ ប្រកសហវ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់ និងដំណើររដ្ឋបាល សម្ភារៈ និងការជួសជុលតូច
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

## សំរេច

**ប្រការ ១ :**

- ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន នៅក្រសួងពាណិជ្ជកម្ម ដែលត្រូវប្រើ ប្រាស់ថវិកាជំពូក ១១ ដើម្បីធ្វើការទូទាត់ការចំណាយទាំងឡាយ ដែលមានចែងក្នុងមាត្រា ៦៤ នៃអនុ ក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃការចំណាយ ដែលអនុញ្ញាតអោយរជ្ជទេយ្យបុរេប្រទាន ធ្វើការទូទាត់ត្រូវបានកំណត់ក្រោម ៥០០.០០០រ០០ ( ប្រាំរយពាន់រៀលគត់) តាមចំណាត់ថ្នាក់ចំណាយ នីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ នឹងប្រកាសអន្តរក្រសួង ។

**ប្រការ ២ :**

- ចំនួនទឹកប្រាក់ នៃរជ្ជទេយ្យបុរេប្រទានជំពូក ១១ សំរាប់មួយជុំ នៃឆ្នាំត្រូវបានកំណត់ត្រឹមចំនួន ១៧១.០០០.០០០រ០០ ( មួយរយចិតសិបមួយលានរៀលគត់) សំរាប់ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ។

**ប្រការ ៣ :**

- សេចក្តីសំរេចទាំងឡាយណាដែល មានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :**

- អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម មានភារកិច្ច ទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត់ ចន្ថា (?)**

**គាត់ ចន**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៤

"ដើម្បីមុខការ"

- ឯកសារ-កាលប្បវត្តិ